# របៀបចាត់ចែងពេលហ្លួងសុវណ្ណគត

អត្ថបទលើកមកបង្ហាញនាពេលនេះ គឺជាអត្ថបទកំណត់ត្រាអំពីទំនៀម ឬរបៀបចាត់ចែងពេលហ្លួងសុវណ្ណគត។ កំណត់ត្រានេះ រក្សាទុកនៅបណ្ណាល័យអាឡាំងសុង (Bibliothèque municipale d'Alençon) ប្រទេសបារាំង ដែលលោក អាដេម៉ារដ៍ ឡឺក្លែរ (Adhémard Leclère) បានប្រមែប្រមូលពីស្រុកខ្មែរទៅ ដែលឯកសារភាគច្រើន ជាឯកសារលោកបញ្ជាឱ្យគេសរសេរតាក់តែង ឯកសារខ្លះទៀតលោកឱ្យគេចម្លងឡើងវិញតាមច្បាប់ដើម។ កំណត់ត្រានេះ បានរៀបរាប់ពីដំណើររៀបចំតាំងពីហ្លួងរៀបនឹងសុវណ្ណគតរហូតដល់ពេលហ្លួងសុវណ្ណគត របៀបចាត់ចែងព្រះបរមសពមុន និងពេលបញ្ចូលកោដ្ឋ[១] និងបែបបទពិធីបុណ្យជាដើម។ អត្ថបទនេះពុំមានចុះកាលបរិច្ឆេទនោះទេ ប៉ុន្តែយើងដឹងថាសរសេរក្នុងរាជ្យព្រះបាទនរោត្តម។

ពាក្យ “សុវណ្ណគត” ជាពាក្យមានប្រភពដើមមកពីពាក្យសំស្ក្រឹតថា “ស្វគ៌ត” ដែលឃើញមានប្រើក្នុងសិលាចារឹកខ្មែរតាំងពីសម័យមុនអង្គរ មានន័យថា “ដែលទៅកាន់ឋានសួគ៌ហើយ”។ នេះជាទំនៀមតាំងពីបរមបុរាណដែលយល់ថាក្រោយពីស្ដេចសោយទិវង្គតហើយព្រះអង្គយាងទៅកាន់ឋានសួគ៌។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះៗតាមរយៈសិលាចារឹកដូចតទៅៈ

- តគិរាជ្យវ្រះកម្រតាងអញ៑តទៅ**ស្វគ៌**គិរបុរ = នៅរាជ្យព្រះបាទគម្តែងអញដ៏ទៅឋានសួគ៌សិវបូរ ឬសម្រាយឱ្យងាយថា នៅក្នុងរាជ្យព្រះបាទជ័យវម៌្មទី១។ វ្រះកម្រតាងអញតទៅស្វគ៌គិរបុរ ជាបច្ឆាមរណនាមព្រះបាទជ័យវម៌្មទី១។ (សិលាចារឹកតាំងក្រាំង K.726)
- វ្រះបាទបរមេឝ្វរ**ស្វគ៌ត**អ្នៅនគរហរិហរាលយ = ព្រះបាទបរមេសូរ (ព្រះបាទជ័យវម៌្មទី២) **សួគ៌ត**នៅនគរហរិហរាល័យ។ (សិលាចារឹកស្ដុកកក់ធំ K.235)

ពាក្យ “ស្វគ៌ត” នេះក្លាយមកជាពាក្យខ្មែរទំនើបពីរពាក្យ។ ទីមួយ គឺក្លាយមកជាពាក្យ “សុគត” ដែលតាមលំនាំពាក្យបុរាណ ដើងវ “◌្វ” ប្រែប្រួលមកជាស្រៈ “◌ូ” និង ស្រៈ

[១] សូមអានបន្ថែម https://sopheak.wordpress.com/2014/09/02/kouath/ និង https://sopheak.wordpress.com/2013/03/21/the-dead-of-royal-urn-in-cambodia/

"◌ួ" ដូចជាពាក្យ "ឥគ្វរ" ក្លាយមកជា "ឥសូរ" និង "ស្វស្តិ" ក្លាយមកជា "សួស្តី" ជាដើម។ ដូច្នេះហើយទើបពាក្យនេះ ក្លាយមកជា "សូគ៌ត" និង "សួគ៌ត"[២] ប៉ុន្តែក្រោយមកមានការកំណត់សំណេរផ្លូវការជា "សុគត" ដែលពាក្យនេះមានន័យថា ដែលទៅហើយដោយស្រួល។ ខ្មែរប្រើពាក្យនេះសំដៅសេចក្តីថា "ទទួលមរណភាពទៅកើតឯឋានល្អហើយ"[៣]។ ទីពីរ គឺក្លាយមកជា "សុវណ្ណគត" ដែលសៀមបានយកពាក្យខ្មែរបុរាណ "ស្វគ៌ត" នេះទៅប្រើ និងបញ្ចេញសំឡេងតាមប្រព័ន្ធសម្តីសៀម[៤] រួចខ្មែរយកពាក្យនោះពីសៀមមកប្រើវិញជា "សុវណ្ណគត" ប៉ុន្តែពាក្យនេះពុំមានកត់ត្រានៅក្នុងវចនានុក្រមខ្មែរឡើយ។ សព្វថ្ងៃយើងនិយមប្រើពាក្យ "សោយទិវង្គត" ជំនួសវិញ។

## អត្ថបទដើមសម្រួលតាមអក្ខរាវិរុទ្ធសម័យទំនើប

***(ទំព័រ១)*** *កាលហ្ជងម្ចាស់ជីវិតរៀបនឹងសុវណ្ណគត នោះលោកកុង្សរិយ៍សេនាបតី និងនាម៉ឺនធំតូច និងពួកអស់អ្នកក្នុងវាំងមានចៅចម ឃុនចម ចៅឃុន និងឃុន អ្នកម្នាង អ្នកនាងជាដើម និងពួកខ្ញុំរាជការខាងក្រៅសម្រាប់បុណ្យព្រះបារមីហ្ជងធំតូចទាំងប៉ុន្មានក៏សឹងតែមកដេកនៅត្រៀមចាំហ្ជងតែសព្វថ្ងៃជានិច្ចពុំដែលដាច់ ហើយរៀបចាត់ចែងឱ្យពួកជាងទងយកមាសសុទ្ធ* ***យីធុងអីម****[៥] យ៉ាងល្អចំនួនមាស៩ជី យកទៅផែឱ្យស្តើង រួចយកមកបៀរសម្រាប់ទុកធ្វើជាសុពណ៌បដ[៦] ឱ្យពួករាជបណ្ឌិត១ សង្ឃរី១ នឹងលោកសង្ឃរាជាគណៈមានល្អងធូលីលោកគ្រូស្តេចជាដើមឱ្យចារ សរសេរបាលីធម៌ឈ្មោះសុពណ៌បដ សម្រាប់ដាក់នៅទ្វារទាំង៩[៧] លុះដល់ហ្ជងម្ចាស់ជីវិតមានកម្លាំងនោះក៏ថយតិចណាស់ គេយក*

[២] *សូមអានបន្ថែម* George Coedès, *២០០៧: ២៨៨*

[៣] *វចនានុក្រមខ្មែរ, ១៩៦៨*

[៤] ***សវរ្ណគត*** *អានថា [សៈ-វ៉ាន់-ឃុត] ទើបខ្មែរប្រើតាមបញ្ចេញសំឡេងជា [សុ-វ៉ាន់-ណាក់-គត់]*

[៥] *ប្រហែលជាប្រភេទមាសម្យ៉ាង ឬជាយីហោមាសល្អនិងល្បីនាសម័យនោះ?*

[៦] *ច្បាប់ដើមសរសេរជា* ***សូព៌ាបាទ*** *ជាបាលីចារលើសន្ទឹកមាសបញ្ចុះទ្វារទាំង៩។ ប៉ុន្តែក្នុងអត្ថបទនេះ បង្ហាញថាដាក់នៅមាត់ ច្រមុះ ថ្ងាស ត្រចៀក និងដើមទ្រូង ពោលត្រឹមតែ៥ប៉ុណ្ណោះ*

[៧] *ទ្វារទាំង៩ បានដល់ទ្វារភ្នែក២ ទ្វារច្រមុះ២ ទ្វារត្រចៀក២ ទ្វារមាត់១ ទ្វារភេទ១ និងទ្វារបាត១*

*អត្ថបទដោយ៖ លោក ហ៊ិន ឈុនតេង*

សំពត់ទេសឯកពាសពីលើដំបូលដំណាក់ទាំងអស់ រួចឱ្យគេយកព្រះបដឱ្យដាងគំនូរគួរជារឿងឋានសួគ៌ទាំងអស់ រួចគេយកទៅបិទបាំងដំបូលដំណាក់ពីលើឱ្យជិតជុំវិញ ឱ្យហ្លួងក្រឡេកមើលទៅឃើញសប្បាយវិញ្ញាណហ្លួងទៅដូចចាប់អារម្មណ៍ជាប់នៅទីនោះ លុះដល់ហ្លួងទ្រង់យាងចូលចុះកាន់ផ្លូវសុវណ្ណគតប្រាកដ មានមនុស្សអ្នកចេះធម៌ ស្គាល់ដំណើរស្គាល់ផ្លូវដែលនៅប្រចាំការនៅទីនោះ ស្រែកប្រាប់ធម៌ប្រាប់ផ្លូវហ្លួង រួចគេដាក់ហ្លួងឱ្យផ្ងំផ្ងារ រួចគេយកមាសដែលចារសរសេរបាលីធម៌ឈ្មោះសុពណ៌បដ ដាក់នៅមាត់១អន្ទើ ច្រមុះ១អន្ទើ ថ្ពាស១អន្ទើ ត្រចៀក១អន្ទើ ដើមទ្រូង១អន្ទើ រួចគេយកទឹកអប់ស្រោចដុសលាងហ្លួងឱ្យជ្រះស្អាតល្អ រួចគេនិមន្តលោកសង្ឃឱ្យសូត្រធម៌សត្តប្បករណ៍បង្សុកូល លុះដល់គេរៀបនឹងរុំសពហ្លួងឱ្យចូលក្នុងព្រះស្ពាន នោះគេរើលាងរូបហ្លួងម្តងទៀត រួចគេយកទឹកបារតចាក់ក្នុងមាត់ហ្លួង រួចគេយកមកុដគ្រឿងមាសសុទ្ធមកបំពាក់រូបហ្លួង និងគ្រឿង **(ទំព័រ២)**សង្វារមាសសុទ្ធគ្រប់ប្រដាប់មកតែងបំពាក់រូបហ្លួង រួចគេឱ្យហ្លួងស្លៀកសំពត់ចរបាប់យ៉ាងថ្លៃ រួចគេយកខ្សែក្រវាត់ខឹមខាត់ពេជ្រយ៉ាងថ្លៃ១ពាន់រៀលឱ្យហ្លួងក្រវាត់ រួចគេយកចិញ្ចៀនត្បូងពេជ្រទាំងគ្រាប់យ៉ាងថ្លៃឱ្យហ្លួងពាក់គ្រប់ម្រាមដៃទាំងអស់ ឯដំណើរដែលគេនឹងតុបតែងរូបហ្លួងនោះ ដូចកាលហ្លួងគង់ព្រះជន្មរស់នៅឡើយ ហើយតែងព្រះអង្គដែលនឹងចេញទទួលគំនាប់លោកហ្គូវែរន័រហ្សេណេរ៉ាល់ (gouverneur général) ឬចេញទទួលគំនាប់លោកឡឺរេស៊ីដង់ត៍ (le résident) ណាៗ លុះតុបតែងរូបហ្លួងស្រេច គេដាក់ឱ្យហ្លួងអង្គុយប្រហោងក្នុងកោដ្ឋមាស រួចគេយកស្ពាន្រ្តួយឱ្យហ្លួងកាន់សំពះអង្គុយប្រហោងប្រណម្យក្នុងកោដ្ឋមាសនោះ ឯកោដ្ឋមាសនោះគេធ្វើខ្ទៅឱ្យទឹកចេញចូលបាន សម្រាប់ឱ្យទឹកសម្អុយខ្ទុះឈាមអសោចលាមកស្រក់ហូរចេញបាន រួចគេយកចាន ឬកែវយ៉ាងធំត្រងពីក្រោម ឯទឹកសម្អុយនោះសន្មតហៅថាទឹកព្រះបុព្វោ ឯរូបសពនោះមានមនុស្សប្រុសស្រីនិងនាម៉ឺនធំតូចដេកវេននៅចាំរក្សាទាំងថ្ងៃយប់ជាប្រក្រតី មើលថែទាំរក្សា ចាំមើលត្រងទឹកសម្អុយនោះនាំយកទៅចាក់ចោលកណ្តាលទន្លេ ហើយមានភ្លេងដង្ហែទឹកសម្អុយនោះនាំយកទៅចាក់ចោលផង ឯទីកន្លែងដែលតម្កល់សពនោះមានពួកស្រីនៅប្រចាំការយំយាមគ្រប់ពេលទាំងថ្ងៃយប់ក្នុង១ថ្ងៃយំយាម៣ដង ១យប់យំយាម៣ដង មានទំនុកនោះផ្សេងៗតទៅ ឯលោកសង្ឃក៏ផ្ចាសគ្នាសូត្រធម្មទេសនាទាំងថ្ងៃយប់ពុំដែលដាច់ៗ "ចប់"

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង



អត្ថបទដើមសន្លឹកទី១ (ប្រភព៖ បណ្ណាល័យអាឡាំងសុង)

អត្ថបទដោយ៖ លោក ហ៊ិន ឈុនតេង



អត្ថបទដើមសន្ទឹកទី២ (ប្រភព៖ បណ្ណាល័យអាឡាំងសុង)

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង




ពាក្យ «ស្វគ៌» និង «ស្វគ៌្គត» នៅក្នុងសិលាចារឹកខ្មែរបុរាណ

## ឯកសារយោង

ពុទ្ធសាសនបណ្ឌិត្យ

១៩៦៨. វចនានុក្រមខ្មែរ ភាគ២, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

បណ្ណាល័យអាឡាំងសុង

https://bibliotheque-numerique-patrimoniale.cu-alencon.fr/records/item/1455-moeurs-cambodgiennes-5-note-sur-ce-qu-il-convient-de-faire-a-la-mort-d-un-roi?offset=200#menu-top

George Coedès

២០០៧. “អង្គរវត្តជាប្រាសាទឬផ្នូរ?”, ប្រែសម្រួលដោយ អាំង ជូលាន ពីអត្ថបទដើមឈ្មោះ “Angkor Vat, temple ou tombeau?”, ឧទ័យ, លេខ៨, ភ្នំពេញ, ទំព័រ ៨១-៨៩។

រើតព្រេសុភ័ក្ត្រ

- https://sopheak.wordpress.com/2013/03/21/the-dead-of-royal-urn-in-cambodia/
- https://sopheak.wordpress.com/2014/09/02/kouath/

អត្ថបទដោយ៖ លោក ហ៊ុន ឈុនតេង